**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ:...១៧៧.............កប/ប្រ.ក

# ប្រកាស

## ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅរបស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុលោមតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹង នៃ ប.ស.ស ដើម្បីដោះស្រាយវិវាទ ឬ បណ្ដឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និង បទបញ្ជាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង បេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ២.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹង នៃ ប.ស.ស មានភារកិច្ចផ្សះផ្សាវិវាទ ដែលទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គមដូចជា៖

- បណ្ដឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងការមិនយល់ព្រម ឬ ភាពមិនត្រឹមត្រូវក្នុងការផ្ដល់តាវកាលិករបបសន្តិសុខសង្គម
- បណ្ដឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងភាពមិនប្រក្រតី នៃការផ្ដល់សេវារបបសន្តិសុខសង្គម
- បណ្ដឹងតវ៉ារបស់កម្មករនិយោជិតសមាជិកប.ស.សចំពោះការខកខានរបស់និយោជកមិនរាយការណ៍ដើម្បីចុះឈ្មោះខ្លួនក្នុង ប.ស.ស
- បណ្ដឹងតវ៉ារបស់និយោជក ចំពោះការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ ឬ បទបញ្ជាជាធរមានរបស់មន្ត្រី ប.ស.ស
- បណ្ដឹងតវ៉ាផ្សេងទៀត ដែលទាក់ទងនឹងការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៣.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹង នៃ ប.ស.ស មានសមាជិកពេញសិទ្ធិ **បី** រូប និង សមាជិកបម្រុង **ប្រាំមួយ** រូប ដូចខាងក្រោម៖

- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក (មួយរូបពេញសិទ្ធិដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ជាប្រធានគណៈកម្មការ មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត ជាសមាជិក និង មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក ជាសមាជិក)

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន សមាជិកបម្រុង ដែលស្នើឡើងដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលតួនាទីជាប្រធានស្តីទី

ក្នុងករណីដែលសមាជិកគណៈកម្មការ នៃភាគីណាមួយអវត្តមាន ប្រធានគណៈកម្មការ ឬ ប្រធានស្តីទី អាចអញ្ជើញសមាជិកបម្រុងដែលតំណាងឱ្យភាគីអវត្តមានចូលរួមប្រជុំ

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ ប្រធានស្តីទី។ ហើយគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានអាណត្តិរយៈពេលមួយឆ្នាំ

ភាសារដែលត្រូវប្រើក្នុងដំណើរការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស គឺភាសារខ្មែរ

ការប្រជុំរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវធ្វើឡើងជាការសម្ងាត់

នីតិវិធីនៃការសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចេញដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**ប្រការ ៤.-**

សមាជិកនៃគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានអាយុយ៉ាងតិច២៥ ឆ្នាំ
- មានការទទួលស្គាល់ អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌
- បទពិសោធន៍ពាក់ព័ន្ធនឹងការងារយ៉ាងតិច០៣ ឆ្នាំ
- បរិញ្ញាបត្រផ្នែកច្បាប់ ឬ មានគុណវឌ្ឍន៍ផ្នែកច្បាប់
- មានចំណេះដឹងអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង បទបញ្ហាផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងវិស័យសន្តិសុខសង្គម ។

**ប្រការ ៥.-**

ប្រធានគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកោះអញ្ជើញភាគីប្តឹងតវ៉ាមកបំភ្លឺ និង ផ្តល់ឯកសារ ឬ ព័ត៌មានចាំបាច់ផ្សេងៗ នៅចំពោះមុខគណៈកម្មការ ។

**ប្រការ ៦.-**

ភាគីប្តឹងតវ៉ា អាចបង្ហាញខ្លួន ចំពោះមុខគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយផ្ទាល់ខ្លួនដែលអាចមានអ្នកអម ឬ ដោយតំណាង ដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាមីបណ្តឹង

ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ត្រូវបានតំរូវអោយចូលរួមផ្សះផ្សាក្នុងម៉ោងធ្វើការ និយោជក ត្រូវតែអនុញ្ញាត បន្ទាប់ពីបានទទួលលិខិតកោះអញ្ជើញ ដោយមិនឲ្យទទួលផលប៉ះពាល់ជាអវិជ្ជមាន ដល់សិទ្ធិកម្មករនិយោជិតនោះឡើយ ។

**ប្រការ ៧.-**

ក្នុងករណីដែលភាគីប្តឹងតវ៉ា ខកខានមិនបានមកបង្ហាញខ្លួនតាមការអញ្ជើញ របស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មការអាចដំណើរការ របស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ឈប់បណ្តឹងតវ៉ាតាមរយៈការចេញសេចក្តីសម្រេច ។

**ប្រការ ៨.-**

ក្នុងរយៈពេល១៥ ថ្ងៃធ្វើការ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវរាយការណ៍ អំពីសេចក្តីសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ជូននាយកបេឡាជាតិរបបសន្តិសុខសង្គម។ នាយក បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់ដំណឹងទៅភាគីប្តឹងតវ៉ាភ្លាម អំពីសេចក្តីសម្រេចនោះដោយផ្ទាល់ ជូនភាគីប្តឹងតវ៉ានោះនូវច្បាប់ចម្លងសេចក្តីសម្រេច ដែលមានបញ្ជាក់ត្រឹមត្រូវចំនួន០១ ច្បាប់

នាយកបេឡាជាតិរបបសន្តិសុខសង្គម អាចមានសិទ្ធិជំទាស់ ឬ បដិសេធសេចក្តីសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ក្នុងករណីដែលសេចក្តីសម្រេចនោះផ្ទុយនឹងច្បាប់ ឬ បទបញ្ញាជាធរមាន ហើយនាយក ប.ស.ស ត្រូវជូនដំណឹងទៅប្រធានគណៈកម្មការ ដើម្បីពិនិត្យករណី នេះសារជាថ្មី។

**ប្រការ ៩.-**

ភាគីប្តឹងតវ៉ាអាចជំទាស់ទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅនាយកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈ ពេលប្រាំបីថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេច។ ក្នុងករណីនេះភាគីប្តឹងតវ៉ាអាចប្តឹងទៅតុលាការ មានសមត្ថកិច្ច ដើម្បីដោះស្រាយបន្ត ។

**ប្រការ ១០.-**

សេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវយកជាបានការ ហើយភាគីប្តឹងតវ៉ាត្រូវអនុវត្តតាម ប្រសិនបើគ្មានការជំទាស់រយៈពេលប្រាំបីថ្ងៃធ្វើការ ។

**ប្រការ ១១.-**

ការចំណាយសម្រាប់ការរៀបចំការប្រជុំគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវនៅក្នុងបន្ទុករបស់ ប.ស.ស ។ លាភការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស ។

**ប្រការ ១២.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទការល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ